

# គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP)

ចេញផ្សាយលេខ៧ ខែមេសា - មិថុនា ឆ្នាំ២០១៥

## ធនាគារស្រូវថ្មីបង្កើនកម្រិតជីវភាពរបស់ប្រជាជនក្នុងសហគមន៍

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) ដែលជាអង្គការដៃគូរបស់គម្រោង CTIP បច្ចុប្បន្ននេះបានបង្កើតធនាគារស្រូវមួយ ដែលជាវិធានការថ្មីមួយក្នុងចំណោមវិធានការថ្មីៗជាច្រើនរបស់គម្រោង CTIP ដើម្បីបង្កើតសំណាញ់សុវត្ថិភាពនៅក្នុងសហគមន៍ក្រីក្រដែលងាយរងគ្រោះទៅនឹងអំពើជួញដូរមនុស្ស និងកាត់បន្ថយចំនួនកុមារនៅខេត្តស្វាយរៀង ដែលត្រូវបានក្រុមគ្រួសាររបស់ពួកគេនាំយកទៅសុំទាននៅប្រទេសវៀតណាម។ ធនាគារស្រូវដើរតួនាទីយ៉ាងសំខាន់នៅក្នុងសហគមន៍ដោយផ្តល់ស្រូវក្នុងតម្លៃទាបទៅកាន់សមាជិក៦០នាក់របស់ខ្លួន ក្នុងពេលដែលមានកង្វះស្បៀង ហើយធនាគារស្រូវនេះក៏ចូលរួមចំណែកក្នុងការរក្សាតម្លៃស្រូវ ដើម្បីជៀសវៀង ពីការទម្លាក់តម្លៃពីឈ្មួញកណ្តាលផងដែរ។



## កម្លាំងមោះមុតរបស់យុវជន

កាលពីត្រីមាស សមាជិកបណ្តាញយុវជនសហគមន៍ដែលទទួលការបណ្តុះបណ្តាលគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II និងជាដៃគូរបស់សម្ព័ន្ធយុវជនខ្មែរ បានរៀបចំការជិះកង់ផ្សព្វផ្សាយក្នុងសហគមន៍ក្នុងខេត្តសៀមរាប។ ក្នុងឱកាសនោះសិស្សសាលាប្រហែល ជា៩០នាក់បានចុះទៅក្នុងភូមិចំនួន៣ ដើម្បីចែកចាយព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស។ ក្នុងខែមិថុនា យុវជនទាំងនោះនឹងរៀបចំការប្រជុំប្រចាំឆ្នាំអំពីបញ្ហាការជួញដូរមនុស្ស។ អគុណដល់ការខំប្រឹងរបស់ពួកគេ!



## ទិន្នន័យសង្ខេបនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II (ឆ្នាំ២០១១ - ២០១៥)

- ចំនួនជនរងគ្រោះដែលត្រូវបានជួយ៖ ១០៦១ នាក់
- ចំនួនជនរងគ្រោះដែលទទួលបានជំនួយក្នុងការធ្វើមាតុភូមិនិវត្តន៍៖ ៥៨៨ នាក់
- ចំនួនជនរងគ្រោះដែលទទួលបានការគាំទ្រក្នុងការដាក់ពាក្យបណ្តឹង៖ ១១៣ នាក់
- ករណីដែលបានបញ្ជូនទៅកាន់ប៉ូលីសដែលទទួលការបណ្តុះបណ្តាល៖ ៤៨ នាក់
- ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណដោយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (តួលេខបានធ្វើបច្ចុប្បន្នភាពនៅខែធ្នូ ឆ្នាំ២០១៤)៖ ៣២ នាក់
- ចំនួនពលករចំណាកស្រុកដែលទទួលបានព័ត៌មានស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព៖ ៥០៤៩ នាក់ ការថយចុះនៃចំនួនកុមារសុំទានក្នុងឃុំគោលដៅ៖ ៧៤%
- ជនរងគ្រោះ និងងាយរងគ្រោះដែលទទួលបានទុនបង្កើតមុខរបរ៖ ៤៣ នាក់(ជនរងគ្រោះ) និងសមាជិកក្រុមជួយខ្លួនឯង ១០៤នាក់ បានទទួលប្រាក់កម្ចីដើម្បីចាប់ផ្តើមមុខរបរ

** តួលេខបានធ្វើបច្ចុប្បន្នភាពក្នុងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥*

## ក្រុមប្រឹក្សាយុវជនក្នុងសាលារៀនបានចូលរួមផ្សព្វផ្សាយ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលដោយគម្រោង CTIP តាមរយៈអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ដែលជាអង្គការដៃគូរបស់គម្រោង នាយកវិទ្យាល័យក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បានសម្រេចចិត្តបង្កើតក្រុមប្រឹក្សាយុវជនមួយក្នុងឆ្នាំ២០០៨។ ថ្ងៃនេះមានសិស្សចំនួន៥០នាក់បានចូលរួមលើកកម្ពស់ចំណេះដឹងទៅលើការធ្វើចំណាកស្រុកដោយសុវត្ថិភាពក្នុងចំណោមក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ដែលមានបំណងធ្វើចំណាកស្រុក។ តួយ៉ាង ស្រុកម៉ាឡៃជាស្រុកដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីព្រំប្រទល់ប្រទេសថៃ ដែលប្រជាជនជាច្រើននាក់ព្យាយាមចាប់យកឱកាសចំណាកស្រុកទៅកាន់ប្រទេសថៃ។ ដូច្នេះគម្រោង CTIP II បានជួយពួកគេឲ្យចេះការពារខ្លួនឯង។



## ក្រុមហ៊ុន Giant Ocean ជាករណីពិសេសមួយក្នុងតំបន់អាស៊ាន

ក្រុមហ៊ុននេសាទយក្សសមុទ្រអន្តរជាតិមួយដែលគេស្គាល់ថា ក្រុមហ៊ុន Giant Ocean គឺជាទីភ្នាក់ងារជ្រើសរើសឯកជនបានចុះបញ្ជីត្រឹមត្រូវទីមួយដែលរងការចោទ និងផ្តន្ទាទោសតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ក្នុងការជួញដូរបុរសនៅលើទូកនេសាទក្នុងតំបន់អាស៊ាន។ លក្ខណៈពិសេសនៅក្នុងករណីនេះបានជម្រុញឲ្យគម្រោង CTIP II ផលិតវីដេអូឯកសារសម្រាប់ធ្វើជាករណីសិក្សាមួយរៀបរាប់អំពីករណីនេះ ក៏ដូចជារៀបរាប់អំពីទិដ្ឋភាពក្នុងតំបន់ និងក្នុងពិភពលោកស្តីពីការជួញដូរបុរសនៅលើទូកនេសាទ និងបញ្ហាប្រឈមផ្សេងៗ ដើម្បីធ្វើយ៉ាងណាឲ្យពលករនេសាទដែលត្រូវគេកេងប្រវ័ញ្ចទទួលបាននូវភាពយុត្តិធម៌។ ឥឡូវ វីដេអូឯកសារនេះត្រូវគេចែកជូន និងផ្សព្វផ្សាយដល់ស្ថាប័នរដ្ឋ និងទីភ្នាក់ងារអន្តរជាតិនានា ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធីក្នុងការការពារបុរសទៅធ្វើការលើកទូកនេសាទឲ្យរួចផុតពីការរំលោភបំពានផ្សេងៗ។



## គម្រោង CTIP II បានជួយដល់ពលករចំណាកស្រុក២២នាក់ ឲ្យទទួលបានប្រាក់សំណងពីទីភ្នាក់ងារជ្រើសរើសឯកជន

កាលពីខែកុម្ភៈ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) ដែលជាអង្គការដៃគូរបស់គម្រោង CTIP II បានជួយពលករចំណាកស្រុក២២នាក់ក្នុងការដាក់ពាក្យបណ្តឹងទាមទារសំណងពីទីភ្នាក់ងារជ្រើសរើសឯកជន។ ពលករចំណាកស្រុកទាំងអស់បានចុះឈ្មោះទៅធ្វើការស្របច្បាប់នៅប្រទេសថៃ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនចំនួនបី។ បន្ទាប់ពីបានធ្វើការនៅរោងចក្រមួយក្នុងប្រទេសថៃអស់រយៈពេលមួយខែដោយប្រើទិដ្ឋាការទេសចរដែលមានសុពលភាពរយៈពេលមួយខែរួចមក ពលករចំណាកស្រុកទាំងនោះបានបង់ប្រាក់ទៅឲ្យទីភ្នាក់ងារទាំងនោះដើម្បីតទិដ្ឋាការរបស់ពួកគេ។ បើទោះជាពលករបានបង់ប្រាក់ឲ្យទីភ្នាក់ងារជ្រើសរើសពលករហើយក្តី ក៏ទីភ្នាក់ងារទាំងនោះមិនបានបន្តទិដ្ឋការឲ្យពួកគេឡើយ ដោយក្បត់នូវពាក្យសន្យា ដែលជាហេតុធ្វើឲ្យទាហានថៃចាប់ និងបញ្ជូនពលករចំណាកស្រុកទាំងនោះទៅកាន់តុលាការ និងត្រូវគេពិន័យជាទឹកប្រាក់១.៩០០ (មួយពាន់ប្រាំបួនរយ) បាតក្នុងមួយនាក់ៗ (ដែលមានតម្លៃប្រហែលជា ៥៩ដុល្លារអាមេរិក)។



នៅពេលដែលស្ថានទូតខ្មែរប្រចាំក្រុងបាងកកបានជួយបញ្ជូនពលករចំណាកស្រុកទាំងនោះឲ្យត្រលប់មកប្រទេសកម្ពុជាវិញ អង្គការ LSCW បានជួយពួកគេក្នុងការដាក់ពាក្យបណ្ដឹងទៅអង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន (AHTJP) ។ សំណុំរឿង ឋិតក្នុងដៃសមត្ថកិច្ចនគរបាលដែលកំពុងធ្វើការសិក្សាស្រាវជ្រាវ និងស៊ើបអង្កេតលើករណីទីភ្នាក់ងារជ្រើសរើសឯកជននោះ។ សំណាងល្អ ដោយមានការជួយពីគម្រោង CTIP II និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន ទីភ្នាក់ងារជ្រើសរើសឯកជននៅកម្ពុជាបានផ្ដល់ប្រាក់សំណងចំនួន ៨.១១០ (ប្រាំបីពាន់មួយរយដប់) ដុល្លារអាមេរិកទៅ ឲ្យពលករចំណាកស្រុកចំនួន ២២នាក់។

## អ្នកបម្រើសេវាកម្សាន្ត គឺជាអ្នកផ្ដល់ព័ត៌មានយ៉ាងសំខាន់ ដើម្បីជួយដល់ជនរងគ្រោះពីអំពើជួញដូរ

ដោយសារតែហានិភ័យនៃការកេងប្រវ័ញ្ច និងអំពើជួញដូរមនុស្សមានកម្រិតខ្ពស់ គម្រោង CTIP II បានចាប់ផ្ដើមធ្វើការបណ្ដុះបណ្ដាលអ្នកបម្រើសេវាកម្សាន្ត ស្ដីពីអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចាប់តាំងពីខែមីនា ឆ្នាំ២០១៥។ ក្នុងអំឡុងពេលបណ្ដុះបណ្ដាល ស្ត្រីបម្រើសេវាកម្សាន្តទាំងនោះបានយល់ដឹងពីការកត់សម្គាល់អ្នកដែលអាចជាជនរងគ្រោះដោយអំពើជួញដូរ និងអ្នកដែលអាចជាមុខសញ្ញាមេខ្យល់ ដំបូន្មានសំខាន់ៗសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព របៀបកំណត់អត្តសញ្ញាណ បញ្ជូនជនរងគ្រោះ និងស្វែងរកជំនួយសម្រាប់ជនរងគ្រោះ។



## គម្រោង CTIP បានគាំទ្រទៅលើការអនុវត្តផែនការសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

តាមរយៈការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង CTIP គណកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) បានសម្ពោធន៍ដាក់ឲ្យប្រើប្រាស់ រចនាសម្ព័ន្ធថ្មីរបស់ខ្លួន និងដាក់ឲ្យអនុវត្តផែនការសកម្មភាពជាតិ ឆ្នាំ ២០១៤- ២០១៨ (NPA) កាលពីខែកុម្ភៈ។ គម្រោង CTIP បានបន្តជួយគាំទ្រដល់ NCCT ដើម្បីរៀបប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធិភាពមួយ ដែលជាការធានានូវការទទួលខុសត្រូវចំពោះការអនុវត្តផែនការ ។



## បន្ទាប់ពីមានការគាំទ្រពីគម្រោង CTIP ប៉ូលីសបានបន្តការចូលរួមវគ្គបណ្ដុះបណ្ដាលដើម្បីប្រឆាំងនឹងអំពើជួញដូរ

គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ CTIP II ដោយមានកិច្ចសហការជាមួយនឹងអគ្គស្នងការនគរបាលជាតិ បានបណ្ដុះបណ្ដាលមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល ចំនួន៥០០នាក់ក្នុងខេត្តគោលដៅចំនួន៧ស្ដីអំពីអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ មុនពេលដែលមានការបណ្ដុះបណ្ដាល មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលមិនដែលបញ្ជូនករណីអំពើជួញដូរមនុស្សនោះទេ ក៏ប៉ុន្តែតាមរយៈការត្រួតពិនិត្យតាមដានបន្ទាប់ពីការបណ្ដុះបណ្ដាលបានបង្ហាញថា ការបណ្ដុះបណ្ដាលផ្ដល់នូវផលវិជ្ជមាន ហើយឥឡូវមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលទាំងនោះមានភាពសកម្មក្នុងការបញ្ជូនករណី។ តួយ៉ាងកន្លងមកមានករណីចំនួន៤៧ ត្រូវបានរាយការណ៍ដោយមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល ដែលបានទទួលការបណ្ដុះបណ្ដាលប៉ុន្តែនៅតែមានករណីមួយចំនួន ដែលពួកគេនៅមិនទាន់កំនត់ថាជាករណីជួញដូរមនុស្សបានច្បាស់លាស់។ តាមរយៈការតាមដាន CTIP II បន្តផ្ដល់ការបណ្ដុះបណ្ដាលបន្ថែមដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលទាំងនោះដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីអំពើជួញដូរមនុស្ស។



ដោយទទួលបានភាពជោគជ័យទៅលើវគ្គបណ្តុះបណ្តាលរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានសម្រេចចិត្តស្នើរសុំថវិកាពីរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលក្រុមរបស់ខ្លួនដោយប្រើប្រាស់សម្ភារៈបណ្តុះបណ្តាលរបស់គម្រោង CTIP II ។ ការបណ្តុះបណ្តាលនេះនឹងចាប់ផ្តើមក្នុងពេលចាប់ៗនេះ។

## ក្រុមជួយខ្លួនឯងនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ CTIP II ក្នុងការងារទប់ស្កាត់កុមារសុំទាន

ក្នុងនាមជាអង្គការដៃគូរបស់គម្រោង CTIP មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) បានជួយគាំទ្រដល់ប្រជាពលរដ្ឋចំនួន ១០៤នាក់ តាមរយៈការបង្កើតក្រុមជួយខ្លួនឯងចំនួន៣ក្រុម។ បន្ទាប់ពីធ្វើការជាមួយគម្រោង CTIP រយៈពេលមួយឆ្នាំកន្លងមក សមាជិកក្រុមជួយខ្លួនឯងទាំងអស់ (១០០%) បានទទួលការងារធ្វើ ក្នុងនោះសមាជិក៦០%បានសងបំណុលរបស់ខ្លួនរួចរាល់ទាំងស្រុង។ តួលេខនៃអ្នកធ្វើទេស្តប្រវេសន៍ និងកុមារបោះបង់ចោលការសិក្សាបានថយចុះគួរឲ្យកត់សម្គាល់ ហើយក្នុងឃុំគោលដៅចំនួន២ ចំនួនកុមារសុំទានក៏មានការធ្លាក់ចុះមកត្រឹមតែ៧៤% ប៉ុណ្ណោះ។



## តើត្រូវស្វែងរកឱកាសការងារនៅប្រទេសកម្ពុជា និងក្រៅប្រទេសរបៀបណា?

តើត្រូវស្វែងរកឱកាសការងារនៅកន្លែងណាក្នុងប្រទេសកម្ពុជា? តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីចំណាកស្រុកដោយស្របច្បាប់ទៅកាន់ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ? តើបច្ចុប្បន្នភាពចុងក្រោយទៅលើដំណើរការផ្ទៀងផ្ទាត់សញ្ជាតិក្នុងប្រទេសថៃមានអ្វីខ្លះ? ដើម្បីទទួលបានចម្លើយនៃសំណួរខាងលើ សូមទំនាក់ទំនងទៅលេខទូរស័ព្ទចំណាកស្រុកដោយសុវត្ថិភាពរបស់ពួកយើងដែលមានលេខ ០៩៥ ៩៧៥ ៨០៤ ។

## លេខទូរស័ព្ទសារជាសំឡេង ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៩៥ ៩៧៥ ៨០៤

អតិថិជនសែលកាតអាចទូរស័ព្ទមកលេខនេះដោយឥតគិតថ្លៃរហូតដល់ ថ្ងៃទី ១០ កក្កដា ២០១៥

## ប្រសិនបើលោកអ្នកជួបប្រទះ ឬធ្លាក់ចូលក្នុងអំពើជួញដូរមនុស្ស លោកអ្នកក៏អាចសាកល្បងស្វែងរកជំនួយតាមរយៈលេខទូរស័ព្ទខាងក្រោម៖

### ក្នុងប្រទេសកម្ពុជា

នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន (AHTJP)៖

០២៣ ៩៩ ៧៩ ១៩ ឬ ១២៨៨ (ទំនាក់ទំនងដោយមិនគិតថ្លៃ)

ការិយាល័យនគរបាលប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៅតាមបណ្តារាជធានី-ខេត្តនានា

| | | | |
|---|---|---|---|
| ភ្នំពេញ | ០១៧ ២៧៦ ២២២ | កំពង់ធំ | ០១៧ ២៥៤ ២២២ |
| សៀមរាប | ០១៧ ២៥៨ ២២២ | បន្ទាយមានជ័យ | ០១៧ ២៦០ ២២២ |
| បាត់ដំបង | ០១៧ ២៣៦ ២២២ | កំពង់ឆ្នាំង | ០១៧ ៣២៦ ២២២ |
| ក្រុងព្រះសីហនុ | ០១៧ ២៥៩ ២២២ | | |

### លេខទូរស័ព្ទទំនាក់ទំនងរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)៖

០៩៨ ៣៦០ ០៤៩ (ប៉ោយប៉ែត) ០៨៨ ៦៩៥ ៤១៧៨ (សៀមរាប)

អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)៖

០៧៧ ៤៥៥ ៥១៦

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)៖

០១២ ៩១៣ ១៣៨

### នៅប្រទេសចិន

ស្ថានទូតកម្ពុជាប្រចាំទីក្រុងប៉េកាំង៖ + ៨៦ ១៨ ៨០ ១៤ ០៧ ៨៦៥

អគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ៖ + ៨៦ ១៥ ៦០ ១៧ ១៨ ៧៧៧

+ ៨៦ ១៨ ៥០ ១៦ ៤៣ ៥៣៧

### នៅប្រទេសថៃ

ស្ថានទូតថៃប្រចាំនៅប្រទេសថៃ៖

+ ៦៦ ២៩ ៥៧៥ ៨៥១

អង្គការសម្ព័ន្ធសកលប្រឆាំងអំពើជួញដូរស្ត្រី (GAATW)៖

+ ៦៦ ២៨ ៦៤១ ៤២៧

អង្គការ LPN ៖

+ ៦៦ ៣៤ ៤៣៤ ២៦៧

### នៅប្រទេសម៉ាឡេស៊ី

ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី៖

+ ៦០ ៣៤ ២៥៧ ១១៥០

+ ៦០ ៣៤ ២៥៧ ៣៧១១

អង្គការទីណាហ្គានីតា

+ ៦០ ៣៧ ៧៧០ ៣៦៩១

### ប្រទេសសិង្ហបុរី

ក្រសួងការងារនៅប្រទេសសិង្ហបុរី

+ ៦៥ ៦៤ ៣៨៥ ១២២ (សម្រាប់សំណួរទូទៅ)

+ ៦៥ ៦៥ ៣៨៦ ៩៣០ (សម្រាប់គុណភាពសេវា)

ទីភ្នាក់ងារពឹងពាក់គុណសម្រាប់អ្នកបម្រើដែលស្នាក់នៅបណ្តោះអាសន្ន (TWC2)

+ ៦៥ ៦២ ៤៧៧ ០០១

អង្គការមនុស្សធម៌សម្រាប់សេដ្ឋកិច្ចនៃការធ្វើទេសន្តរប្រវេសន៍ (HOME)

លេខទំនាក់ទំនងផ្តល់ជំនួយ២៤ម៉ោងសម្រាប់ពលករស្ត្រី និងបុរសជនជាតិបរទេស

+ ៦៥ ៦៣ ៤១៥ ៥២៥ (ស្ត្រី)

+ ៦៥ ៦៣ ៤១៥ ៥៣៥ (បុរស)

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកផលកំរ៉ៃ ដែលធ្វើការជាមួយប្រជាជននៅសហរដ្ឋអាមេរិក និង
នៅទូទាំងពិភពលោក ដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិអោយបានគង់វង្ស។

WINROCK INTERNATIONAL
Putting Ideas to Work

ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា

មជ្ឈមណ្ឌលភ្នំពេញ អគារ អែហ្វ បន្ទប់លេខ ៧៨៧ មហាវិថី សុធារស រាជធានីភ្នំពេញ ទូរស័ព្ទ: +៨៥៥-២៣ ២១២ ៣៣៤/៦ ទូរសារ: +៨៥៥-២៣ ២១២ ៣៣៥

សារអេឡិចត្រូនិច: ctip@winrock.org គេហទំព័រ: www.winrock.org